22/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

រឿងក្តីលេខ ៧៣២ ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១១
សញ្ញាណរឿងក្តី ៖ ប្តឹងទាមទារប្រាក់ និងបែងចែកភាគហ៊ុន
ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១
សាលក្រមលេខ ៥៥ "ច"
ថ្ងៃប្រកាសសាលក្រមថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ
## ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ

ដើមចោទឈ្មោះ [redacted] ចាន់ថា ភេទប្រុស អាយុ ៥៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៩ អាអ៊ី០ ផ្លូវលេខ ១១១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិលោកស្រី [redacted] មានការិយាល័យនៅផ្ទះលេខ ១៣១A ផ្លូវលំ ភូមិតាងូវ សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ចុងចម្លើយឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ ៥៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ២០២អា ផ្លូវលេខ ៣១០ សង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិលោក [redacted] មានការិយាល័យនៅអគារលេខ ១៥៩ DE₀ ផ្លូវលេខ ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

### អង្គហេតុ និងចំណុចវិវាទ

**១. ការទាមទាររបស់គូភាគី**

១.១. ការទាមទាររបស់ដើមចោទ

ក. ឲ្យចុងចម្លើយប្រគល់ប្រាក់ចំនួន ២៤.៨៣៥ (ពីរម៉ឺនបួនពាន់ប្រាំបីរយសាមសិបប្រាំ) ដុល្លាអាមេរិក

ខ. ឲ្យចុងចម្លើយសងការខូចខាតជម្ងឺចិត្តចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក

គ. សុំប្រកាសអនុវត្តជាបណ្តោះអាសន្ន

ឃ. ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី

១.២. ការទាមទារក្នុងបណ្តឹងតបរបស់ចុងចម្លើយ

ក. ឲ្យដើមចោទសងប្រាក់ចំនួន ១៨.០០០ (មួយម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក

ខ. ឲ្យដើមចោទប្រគល់រថយន្ត ១ គ្រឿងម៉ាក Toyota Highlander ផលិតឆ្នាំ ២០០២ ពណ៌ខ្មៅ មានលេខតួ JTHF21A720076057 និងលេខម៉ាស៊ីន 1MD1355363 ។



Scanned with CamScanner

គ. សុំប្រកាសអនុវត្តជាបណ្ដោះអាសន្ន
ឃ. ឲ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្ដី

## ២. ការពន្យល់ត្រួសៗអំពីរឿងក្ដី

២.១. នៅក្នុងរឿងក្ដីនេះដើមចោទសុំទាមទារដូចក្នុងចំណុចទី ១.១. "ការទាមទាររបស់ដើមចោទ" ខាងលើដោយហេតុថាដើមចោទ និងចុងចម្លើយបានរកស៊ីចូលហ៊ុនគ្នាទិញលក់រថយន្ត ដោយបានទិញរថយន្តចំនួន ៤ គ្រឿងសម្រាប់លក់ មានរថយន្តម៉ាក CAMRY XLE 2002 ពណ៌ទឹកប្រាក់ តម្លៃ ១៦.៥០០ ដុល្លារអាមេរិក រថយន្តម៉ាក CAMRY XLE 2003 ពណ៌ស្គរ តម្លៃ ១៧.៣០០ ដុល្លារអាមេរិក រថយន្តម៉ាក CAMRY HYBRID 2010 ពណ៌ខ្មៅ តម្លៃ ៣៦.៥០០ ដុល្លារអាមេរិក និងរថយន្តម៉ាក CAMRY XLE 2010 ពណ៌ស្លែ តម្លៃ ៣៦.៥០០ សរុបទឹកប្រាក់ចំនួន ១០៥.៣០០ ដុល្លារអាមេរិក ក្នុងនោះដើមចោទបានចេញប្រាក់ដើមចំនួន ៧២.៣០០ ដុល្លារអាមេរិក ហើយចុងចម្លើយចេញប្រាក់ដើមចំនួន ៣៣.០០០ ដុល្លារអាមេរិក នៅពេលលក់រថយន្តម៉ាក CAMRY HYBRID 2010 ពណ៌ខ្មៅ តម្លៃ ៣៦.៥០០ ដុល្លារអាមេរិក ចុងចម្លើយបានដកយកប្រាក់ដើមរបស់ខ្លួនវិញរួចហើយ ដូច្នេះរថយន្តដែលនៅសល់ ៣ គ្រឿងទៀតជារបស់ដើមចោទទាំងអស់ ប៉ុន្តែនៅពេលលក់រថយន្តម៉ាក CAMRY XLE 2003 ពណ៌ស្គរ តម្លៃ ១៧.៣០០ ដុល្លារអាមេរិក ចុងចម្លើយមិនព្រមប្រគល់ប្រាក់ថ្លៃលក់រថយន្តនោះមកឲ្យដើមចោទវិញទេ ។ ចំណែកឯភាគហ៊ុនផ្សេងទៀតដែលនៅសល់ ត្រូវបែងចែកទូទាត់ផ្ដាច់ពីគ្នា មានដូចតទៅ ៖

ករណីទី១ រថយន្ត ៥ គ្រឿង ដើមចោទចេញប្រាក់ដើម ៣ គ្រឿង ស្មើ ៨៧.០០០ ដុល្លារអាមេរិក ចំណែកចុងចម្លើយចេញប្រាក់ដើម ២ គ្រឿង ស្មើ ៦៣.០០០ ថ្លៃជួសជុល ៥.៧៦២ ដុល្លារអាមេរិក ចុងចម្លើយជាអ្នកចេញដូច្នេះដើមចោទត្រូវប្រគល់ប្រាក់ថ្លៃជួសជុលចំនួន ៥.៧៦២ ដុល្លារអាមេរិក ទៅចុងចម្លើយវិញ

ករណីទី២ រថយន្តម៉ាក FORD តម្លៃដើម ២៧.៤០០ ដុល្លារអាមេរិក ដើមចោទ និងចុងចម្លើយចេញប្រាក់ដើមម្នាក់ពាក់កណ្ដាល ពេលលក់រថយន្តបានចុងចម្លើយបានយកប្រាក់ទាំងអស់ ដូច្នេះចុងចម្លើយត្រូវប្រគល់ប្រាក់ដើមចំនួន ១៣.៧០០ ដុល្លារអាមេរិក មកឲ្យដើមចោទវិញ ។

ករណីទី៣ រថយន្តម៉ាក CAMRY 2010 តម្លៃ ៤៥.០០០ ដុល្លារអាមេរិក ដើមចោទ និងចុងចម្លើយចេញប្រាក់ដើមម្នាក់ពាក់កណ្ដាល ពេលលក់រថយន្តបានដើមចោទទទួលបានប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិក ហើយចុងចម្លើយទទួលបានប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក ដោយអ្នកទិញនៅខ្វះចំនួន ១៥.០០០ ដុល្លារអាមេរិក ដូច្នេះចុងចម្លើយត្រូវប្រគល់ប្រាក់ចំនួន ១២.៥០០ ដុល្លារអាមេរិកមកដើមចោទវិញ

ករណីទី៤ ចំពោះសាច់ប្រាក់សុទ្ធ ដើមចោទបានចេញចំនួន ៣៩.៣៣២ ដុល្លារអាមេរិក ហើយចុងចម្លើយបានចេញចំនួន ៥២.២៣៥ ដុល្លារអាមេរិក ដូច្នេះដើមចោទត្រូវប្រគល់ប្រាក់ចំនួន ១២.៩០៣ ដុល្លារអាមេរិក ឲ្យទៅចុងចម្លើយវិញ ។

ដូច្នេះចុងចម្លើយត្រូវប្រគល់ប្រាក់មកឲ្យដើមចោទវិញចំនួន ២៤.៨៣៥ ដុល្លារអាមេរិក ដែលមានប្រាក់ថ្លៃលក់រថយន្តម៉ាក CAMRY XLE 2003 ពណ៌ស្គរ តម្លៃ ១៧.៣០០ ដុល្លារអាមេរិក ដែលចុងចម្លើយបានទទួលស្គាល់ក្នុងកំណត់ហេតុផ្សះផ្សារសម្រុះសម្រួល ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១១ នៅសាលា



៩៩៣

ខណ្ឌចំការមន និងប្រាក់ថ្លៃទូទាត់ភាគហ៊ុនផ្សេងទៀតចំនួន ៧.៥៣៥ ដុល្លារអាមេរិក សរុបទាំងអស់ចំនួន ២៤.៨៣៥ ដុល្លារអាមេរិក ។

ចុងចម្លើយ បានប្តឹងទាមទារដូចក្នុងចំណុច ១.២. ការទាមទារក្នុងបណ្តឹងតបរបស់ចុងចម្លើយ ដោយហេតុថា ខ្លួននិងដើមចោទបានរកស៊ីទិញលក់រថយន្តជាមួយគ្នា តែដើមចោទពុំបានទូទាត់មកខ្លួនវិញ ។ ដើមចោទបានយករថយន្ត ១ គ្រឿងម៉ាក TOYOTA HIGHLANDER ផលិតឆ្នាំ ២០០២ ពណ៌ខ្មៅ មានលេខតួ JTHF21A720076057, លេខម៉ាស៊ីន 1MD1355363 ក្រដាសពន្ធ ទៅរក្សាទុកនៅទីតាំងឃ្លាំងរបស់ដើមចោទ ដែលរថយន្តនេះជាកម្មសិទ្ធរបស់ខ្លួន ។

កាលពីថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១០ ខ្លួននិងដើមចោទបានទិញរថយន្តចំនួន ៤ គ្រឿង ដោយចែកគ្នាចេញថ្លៃរថយន្តម្នាក់ ២ គ្រឿង (ខ្លួនចេញថ្លៃ TOYOTA CAMRY XLE 2002 ពណ៌ទឹកប្រាក់ ១៦៥០០ ដុល្លារ, TOYOTA CAMRY HIBRID 2010 ៣៦.៥០០ ដុល្លារ ដើមចោទចេញថ្លៃ TOYOTA CAMRY 2010 ពណ៌ស្លែ ៣៥.០០០ ដុល្លារ, TOYOTA CAMRY XLE 2003 ១៧.៣០០ ដុល្លារ) ។ រថយន្តដែលបានលក់ ៣ គ្រឿងដំបូងគឺបានទូទាត់ប្រាក់ដើម និងប្រាក់ចំណេញជាមួយគ្នាអស់ហើយ ចំពោះរថយន្តដែលបានលក់ចុងក្រោយគេ TOYOTA CAMRY XLE 2002 ពណ៌ប្រាក់ ១៦.៥០០ ដុល្លារ ដែលដើមចោទបានលក់ចេញរួចរាល់ហើយ ប៉ុន្តែដើមចោទពុំទាន់បានទូទាត់ប្រាក់ដើម និងប្រាក់ចំណេញមកឱ្យខ្លួននៅឡើយទេ ដោយដើមចោទអះអាងថា រថយន្តនោះគាត់ជាអ្នកចេញប្រាក់សងគេ តែតាមពិតរថយន្តនេះខ្លួនជាអ្នកចេញសង ព្រោះភាគីហ៊ុនទាំងពីរបានព្រមព្រៀងគ្នាទូទាត់កាត់កងលុយគ្នាដែលបានគិតបញ្ជីជាមួយគ្នានៅថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១០ ដោយកាត់កងឡាន TOYOTA CAMRY XLE 2002 ពណ៌ប្រាក់ដាក់ជាកម្មសិទ្ធខ្លួនជាអ្នកចេញប្រាក់សង ហើយមានបញ្ជាក់ឈ្មោះខ្លួនជាអ្នកចេញសងថ្លៃឡាននេះក្នុងបញ្ជីជាលាយល័ក្ខអក្សរទាំងសងខាង ហើយថ្លៃជួសជុលឡាននេះក៏ខ្លួនជាអ្នកចេញថ្លៃជួសជុលទាំងស្រុងដែរ ។

អង្គហេតុមួយទៀតដែលទាក់ទងនឹងរថយន្តម៉ាក TOYOTA HIGHLANDER ឆ្នាំ ផលិត ២០០២ ពណ៌ខ្មៅ មានលេខតួ JTHF21A720076057, លេខម៉ាស៊ីន 1MD1355363 ក្រដាសពន្ធ ជារថយន្តដែលខ្លួនជាអ្នកចេញមុខទិញ ហើយចេញសោហ៊ុយជួសជុលដោយខ្លួនឯង ប៉ុន្តែដើមចោទបែរជាយករថយន្តនេះទៅទុកនៅក្នុងឃ្លាំងឡានរបស់ដើមចោទទៅវិញ ។

**២.២. ចំណុចវិវាទ**

១. តើចុងចម្លើយបានចេញប្រាក់ថ្លៃទិញរថយន្តម៉ាក CAMRY XLE 2002 ពណ៌ទឹកប្រាក់ តម្លៃ ១៦.៥០០ ដែរឬទេ?

២. តើដើមចោទបានទទួលប្រាក់ក្នុងករណីទី៣ចំណុច "គ" ដែលជាប្រាក់បែងចែកភាគហ៊ុនក្នុងពាក្យបណ្តឹងចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១១ របស់ដើមចោទចំនួន ១០.០០០ ដុល្លារអាមេរិក ឬចំនួន ១២.០០០ ដុល្លារអាមេរិក?

<u>**សំអាងហេតុ**</u>

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖



៩៤៦៤

Scanned with CamScanner

**ចំពោះចំណុចវិវាទទី ១ ៖** តើចុងចម្លើយបានចេញប្រាក់ថ្លៃទិញរថយន្តម៉ាក CAMRY XLE 2002 ពណ៌ទឹកប្រាក់ តម្លៃ ១៦.៥០០ ដែរឬទេ?

១. ដើមចោទបានអះអាងថាខ្លួនជាអ្នកបានចេញប្រាក់ថ្លៃទិញរថយន្តម៉ាក CAMRY XLE 2002 ពណ៌ទឹកប្រាក់ តម្លៃ ១៦.៥០០ ។ ចំពោះក្រដាសដែលសរសេរថា ហ៊ីម ចេញ ១៦៥០០ ដុល្លារ គឺគ្រាន់តែកត់ប៉ុណ្ណោះ ដោយដំបូងចុងចម្លើយថាសុំចេញ ប៉ុន្តែការពិតចុងចម្លើយមិនបានចេញទេ ។ ការអះអាងរបស់ដើមចោទនេះមានហេតុផលគួរឱ្យតុលាការជឿបាន ព្រោះថាមានភាពស៊ីសង្វាក់ទៅនឹងបញ្ជីទូទាត់ប្រាក់ថ្លៃទិញរថយន្តចំនួន ៤ គ្រឿង ដែលបញ្ជាក់ថាប្រាក់ថ្លៃទិញរថយន្តសរុបទាំងអស់ ចំនួន ១០៥.៣០០ ដុល្លារ ដែលទឹកប្រាក់ទាំងអស់នេះ ចុងចម្លើយ (ហ៊ា ហ៊ីម) បានចេញចំនួន ៣៣០០០ ក្រៅពីនេះគឺដើមចោទជាអ្នកចេញឱ្យទៅអ្នកលក់ឈ្មោះ LAV SIHVONG ។ ហើយឯកសារនេះក៏ស្របទៅនឹងបញ្ជីទូទាត់ថ្លៃរថយន្តចំនួន ៤ គ្រឿង រវាងដើមចោទ ចុងចម្លើយ ហើយក៏ស្របទៅនឹងលិខិតបំភ្លឺរបស់ឈ្មោះ LAV SIHVONG ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១១ ផងដែរ ។

២. ការអះអាងរបស់ចុងចម្លើយថា ខ្លួនជាអ្នកបានចេញប្រាក់ថ្លៃទិញរថយន្តម៉ាក CAMRY XLE 2002 ពណ៌ទឹកប្រាក់តម្លៃ ១៦.៥០០ គឺពុំមានភស្តុតាងច្បាស់លាស់គួរឱ្យតុលាការជឿបានឡើយ ។

៣. តាមសំអាងហេតុខាងលើបញ្ជាក់ថាចុងចម្លើយមិនបានចេញប្រាក់ថ្លៃទិញរថយន្តម៉ាក CAMRY XLE 2002 ពណ៌ទឹកប្រាក់ តម្លៃ ១៦.៥០០ ទេ ។

**ចំពោះចំណុចវិវាទទី ២ ៖** តើដើមចោទបានទទួលប្រាក់ក្នុងករណីទី៣ចំណុច "គ" ដែលជាប្រាក់បែងចែកភាគហ៊ុនក្នុងពាក្យបណ្តឹងចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១១ របស់ដើមចោទចំនួន ១០.០០០ ដុល្លារអាមេរិក ឬចំនួន ១២.០០០ ដុល្លារអាមេរិក ?

៤. ដើមចោទបានអះអាងថា ក្នុងការបែងចែកភាគហ៊ុន ដូចក្នុងករណីទី ៣ ចំណុច "គ" ខ្លួនបានទទួលតែចំនួន ១០.០០០ ដុល្លារប៉ុណ្ណោះ គឺមិនមែន ១២.០០០ ដុល្លារនោះទេ ។ ប៉ុន្តែចុងចម្លើយបានអះអាងថាដើមចោទបានទទួលប្រាក់ចំនួន ១២០០០ ដុល្លារ ដែលការប្រគល់នេះមានពីរដំណាក់កាល គឺលើកទី ១ នៅថ្ងៃទី ១៣.១២.២០១០ ចំនួន ១០០០០ ដុល្លារ និងថ្ងៃទី ១.២.២០១១ ចំនួន ២០០០ ដុល្លារ ដែលការអះអាងរបស់ចុងចម្លើយនេះគួរឱ្យជឿបាន ។

៥. ដើមចោទទាមទារប្រាក់ពីចុងចម្លើយចំនួន ២៤.៨៣៥ ដុល្លារ ដែលចំនួននេះដើមចោទបានអះអាងថា ខ្លួនបានទទួលប្រាក់បែងចែកភាគហ៊ុនចំនួនតែ ១០០០០ ដុល្លារ ប៉ុន្តែតាមការពិតដើមចោទបានទទួលចំនួន ១២០០០ ដុល្លារ ដូចក្នុងសំអាងហេតុត្រង់ចំនុចទី ៤ ខាងលើ ដូច្នេះគប្បីដកចំនួន ២០០០ ដុល្លារពីការទាមទាររបស់ដើមចោទវិញ ។

៦. ដើមចោទបានទាមទារជម្ងឺចិត្ត ការខាតបង់ពេលវេលា ចំនួន ១០០០០ ដុល្លារអាមេរិក គប្បីតុលាការពិចារណា និងសម្រេចទៅតាមភាពសមរម្យ ។

៧. បណ្តឹងតបរបស់ចុងចម្លើយមិនមានហេតុផលសមរម្យឡើយ ដូច្នេះគប្បីតុលាការច្រានចោលការទាមទារក្នុងបណ្តឹងតបរបស់ចុងចម្លើយ ។

៨. ការសុំរបស់ដើមចោទឱ្យតុលាការប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្ន គឺពុំមានភាពចាំបាច់ឡើយ ដែលគប្បីតុលាការសម្រេចច្រានចោល ។



Scanned with CamScanner

៩. ប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១. ឱ្យចុងចម្លើយឈ្មោះ [redacted] អ៊ីម ៖

ក. សងប្រាក់ចំនួន ២២៨៣៥ (ពីរម៉ឺនពីរពាន់ប្រាំបីរយសាមសិបប្រាំ) ដុល្លារអាមេរិក និង

ខ. បង់ជម្ងឺចិត្តចំនួនស្មើនឹង ២០០០ (ពីរពាន់) ដុល្លារអាមេរិក ទៅដើមចោទឈ្មោះ [redacted] ចាន់ថា ។
ច្រានចោលការទាមទារលើសពីនេះ ។

២. ច្រានចោលការទាមទារក្នុងបណ្តឹងតបរបស់ចុងចម្លើយ ។

៣. ច្រានចោលការសុំឱ្យប្រកាសអនុវត្តជាបណ្តោះអាសន្នរបស់ដើមចោទ ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយទៅតាមភាគដែលចាញ់ក្តី ។

ចៅក្រម

ហត្ថលេខា និងត្រា: [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១១

បានឃើញ

ចៅក្រម

[redacted]

ក្រឡាបញ្ជី

[redacted]